# សញ្ញាដែលអាចឲ្យដឹងថាលោកអ្នកអាចមានរោគហើមសួត

**Warning Siogns of Pneumonia**
**WUML**
**11/5/06**

ការហើមសួតអាចបណ្តាលមកពីស្រទាប់សួតដែលរលាក ដោយសារមេរោគវៃរើស, បាក់តេរី, ឬមេរោគផ្សេងៗទៀតមករាតត្បាត។ ការព្យាបាលឲ្យបានទាន់ពេលវេលា ជាកត្តាមួយសំខាន់បំផុត ក្នុងការជួយឲ្យអ្នកជម្ងឺ បានជៀសផុតពីគ្រោះថ្នាក់ពីរោគហើមសួត (Pneumonia) ។

លំដាប់តទៅនេះជា សញ្ញាឬអាការៈខ្លះៗ ដែលបណ្ណាល័យជាតិនៃសហរដ្ឋផ្នែកខាងវិជ្ជាពេទ្យ U.S. National Library of Medicine បានផ្តល់ ដើម្បីឲ្យលោកអ្នកគួរចាប់អារម្មណ៍និងជ្រាប។ រោគហើមសួត អាចធ្វើឲ្យមនុស្សយើង៖

- ក្អក ហើយមានកំហាកពណ៌បៃតងឬពណ៌លឿង, ឬក្អកមានធ្លាក់ឈាម
- ឈឺដើមទ្រូង ជាពិសេសឈឺខ្លាំង នៅពេលណាដែលក្អកម្តងៗ
- រោគហើមសួតធ្វើឲ្យយើងពិបាកដកដង្ហើម រួមទាំងដកដង្ហើមដង្ហក់ៗ ឬដកដង្ហើយញាប់ពេកផង
- វាធ្វើគ្រុនក្តៅ, រងាញាក់, ឈឺក្បាល, ល្ងិល្ងើវង្វេងវង្វាន់ (ជាពិសេស ចំពោះ អស់លោក ចាស់ទុំ) និងអស់កម្លាំងល្ហិតល្ហៃ។
- ម្យ៉ាងទៀត, រោគហើមសួត ធ្វើឲ្យយើងបែកញើសស្អិត នៅលើស្បែក ផង។

ដូច្នេះ ប្រសិនបើ អស់លោក-លោកស្រី ឬកូនចៅ មានសញ្ញា ឬអាការៈរោគដែលខ្ញុំបាទ បាន អធិប្បាយមកនេះ សូមមេត្តាអញ្ជើញទៅជួបជាមួយគ្រូពេទ្យរបស់លោកអ្នកជាបន្ទាន់។ អាការៈ ដែលលោកអ្នកមានខ្លះ ក៏អាចជាសញ្ញានៃរោគដទៃទៀតបានដែរ។ មានតែគ្រូពេទ្យទេដែលអាច ធ្វើការវិវនិច្ឆ័យរោគទាំងនោះបាន។

*អត្ថបទនេះដកស្រង់និងបកប្រែចេញពីសារពត៌មាន Healthfinder នៃ ក្រសួងសុខភាព និងមនុស្សធម៌ U.S. Department of Health and Human Services។ ដោយ មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាព សហគមន៍ក្រុងឡូវែល។*

http://www.healthfinder.gov/news/newsstory/asp?Doc ID=535745